# ជ្រុងមួយនៃការជំរុញដល់ការស្តារ និងការអភិវឌ្ឍន៍របស់ប្រទេសឥណ្ឌា

ដោយ បណ្ឌិត វង់ សំអូន
ជំនួយការខុទ្ទកាល័យប្រធានរាជបណ្ឌិត្យសភាកម្ពុជា



**រូបភាព៖ការចូលរួមក្នុងការបណ្តុះបណ្តាលគោលនយោបាយសាធារណៈ និងអភិបាលកិច្ចល្អ**

ប្រទេសឥណ្ឌាមានប្រជាជន១៤០០លាននាក់ មានរដ្ឋ (ខេត្ត) ចំនួន ២៨រដ្ឋ ៧៦៤ស្រុក ៧៦៥៤ឃុំ ២៥២០០០ភូមិ ១២ សហគមន៍ ១៧ភាសាដែលត្រូវបានប្រើប្រាស់ជាផ្លូវការ និង៤០%នៃប្រជាជនសរុបរស់នៅក្រោមខ្សែបន្ទាត់សេដ្ឋកិច្ច (យោងតាមការធ្វើបទបង្ហាញរបស់ថ្នាក់ដឹកនាំរដ្ឋបាលនៅទីក្រុងមូសូរីកាលពីថ្ងៃចន្ទទី១ ខែមករា ឆ្នាំ២០២៤)។ ប្រទេសឥណ្ឌាបានប្រើប្រាស់យន្តការជាច្រើននៅក្នុងការស្តារ និងអភិវឌ្ឍន៍ប្រទេសរបស់ខ្លួនក្រោយពីទទួលបានឯករាជ្យពីអាណានិគមនិយមអង់គ្លេសនៅក្នុងឆ្នាំ១៩៤៧។ យន្តការមួយចំនួននៅក្នុងចំណោមយន្តការទាំងនោះរួមមាន៖

**១. យន្តការក្នុងការផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋ ក្នុងការបើកគណនីធនាគារ៖** យោងតាមការធ្វើបទបង្ហាញដោយថ្នាក់ដឹកនាំជំនាញរដ្ឋបាលសាធារណៈ របស់រដ្ឋាភិបាលឥណ្ឌាក្នុងកំឡុងពេលនៃការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងគោលនយោបាយសាធារណៈ និងអភិបាលកិច្ចល្អជូនដល់មន្ត្រីរាជការស៊ីវិលមកពីរាជបណ្ឌិត្យសភាកម្ពុជា និងក្រសួងធម្មការ និងសាសនា បានចង្អុលបង្ហាញថា រដ្ឋាភិបាលឥណ្ឌាបានបង្កើតអែបមួយដែលមានឈ្មោះថា អាដហា (Aadhaar)។ អែបនេះ

បានដើរតួសំខាន់ៗ ៣យ៉ាង រួមមាន៖ ទី១ ផ្ទុកទិន្នន័យប្រវត្តិរូបរបស់ពលរដ្ឋម្នាក់ៗ ទី២ ផ្សារភ្ជាប់ទិន្នន័យនេះនៅក្នុងការបើកគណនី ឬ តម្រូវការនៃការប្រើប្រាស់ឯកសាររបស់ពលរដ្ឋម្នាក់ៗ និង ទី៣ ភ្ជាប់ទិន្នន័យទាំងនេះទៅនឹងទូរស័ព្ទដៃ។ យន្តការនេះ បានធ្វើឱ្យប្រជាជនឥណ្ឌាស្ទើរគ្រប់ស្រទាប់វណ្ណៈ គ្រប់វ័យ និងគ្រប់ទីកន្លែងអាចបើកគណនីបានដោយខ្លួនឯងគ្រប់ពេលវេលាទាំងថ្ងៃសៅរ៍និងអាទិត្យ។ ប្រជាជនឥណ្ឌាគឺជាប្រជាជនដែលពូកែសន្សំប្រាក់ជាងគេលើពិភពលោក ហើយប្រាក់ទាំងនោះត្រូវបានដាក់បញ្ចូលក្នុងគណនីរបស់ខ្លួន។ យន្តការនេះបានជួយដល់រដ្ឋាភិបាលឥណ្ឌាមានថវិកាតាមរយៈការលក់ទូរស័ព្ទដៃដែលផលិតក្នុងស្រុក និងទាញយកប្រយោជន៍ពីការដាក់ប្រាក់ក្នុងគណនីដោយប្រយោលដើម្បីធ្វើការស្តារ និងការអភិវឌ្ឍន៍ប្រទេសជាបន្តបន្ទាប់។

**២. ការអនុវត្តយុទ្ធសាស្ត្រការកសាងផ្លូវជាចម្បង៖** យោងតាមការធ្វើបទបង្ហាញដោយទីប្រឹក្សាសេដ្ឋកិច្ចម្នាក់របស់រដ្ឋាភិបាលឥណ្ឌាកាលពីព្រឹកថ្ងៃសុក្រ ទី៥ ខែមករា ឆ្នាំ២០២៤ នៅទីក្រុងញ៉ូដេលីបានបង្ហាញថា យុទ្ធសាស្ត្រដ៏ចម្បងមួយទៀតរបស់រដ្ឋាភិបាលឥណ្ឌានៅក្នុងការកសាងប្រទេសក្រោយពីទទួលបានឯករាជ្យគឺការកសាងផ្លូវថ្នល់ឱ្យក្លាយជាសរសៃឈាម ដើម្បីតភ្ជាប់គ្រប់តំបន់ទាំងអស់នៅក្នុងប្រទេសឥណ្ឌា។ រដ្ឋាភិបាលឥណ្ឌាបានប្រើប្រាស់ថវិកាដែលទទួលបានពីយន្តការខាងលើដើម្បីកសាងផ្លូវគ្រប់ទីកន្លែងនៅក្នុងប្រទេស។ រដ្ឋាភិបាលឥណ្ឌាបានបញ្ជាក់ថា កាលណាមានផ្លូវគឺមានអ្វីៗទាំងអស់។ ផ្លូវអាចជួយឱ្យរដ្ឋាភិបាលតភ្ជាប់អគ្គិសនី បង្កើតប្រព័ន្ធធារាសាស្ត្រ បង្កើនការដឹកជញ្ជូន បង្កើនសង្វាក់ផលិតកម្ម (គ្មានផ្លូវ គឺគ្មានអគ្គិសនី គ្មានទឹក គ្មានការដឹកជញ្ជូន គ្មានសង្វាក់ផលិតកម្ម ផលិតផលត្រូវខូចខាតរាប់លានតោនជាពិសេសទឹកដោះគោស្រស់ ដំណាំកសិកម្ម.....)។ល។ យន្តការនេះបានជួយយ៉ាងខ្លាំងដល់ការស្តារសេដ្ឋកិច្ចឡើងវិញរបស់ប្រទេសឥណ្ឌាពីព្រោះប្រជាពលរដ្ឋមានផ្លូវ មានអគ្គិសនី មានទឹក និងអាចចល័តផលិតផលបានរហ័ស និងគ្រប់ទីកន្លែង។

**៣. យន្តការនៃការកែប្រែការអនុវត្តគោលនយោបាយសារធារណៈ និងអភិបាលកិច្ចល្អ៖** ឥណ្ឌាបានបន្តការអនុវត្តគោលនយោបាយសារធារណៈ ដែលត្រូវបានបន្សល់ទុកដោយអាណានិគមនិយមអង់គ្លេស និងបានធ្វើបច្ចុប្បន្នភាពគោលនយោបាយទាំងនោះជាបន្តបន្ទាប់ដើម្បីឆ្លើយតបទៅនឹងតម្រូវនៃការអភិវឌ្ឍន៍ប្រទេសរបស់ខ្លួន។ បច្ចុប្បន្ន ការអនុវត្តគោលនយោបាយសាធារណៈរបស់រដ្ឋាភិបាលឥណ្ឌាបានផ្តោតសំខាន់លើការប្រើប្រាស់បច្ចេកវិទ្យានៅគ្រប់កម្រិតថ្នាក់ ចាប់តាំងពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់ជាតិដើម្បីផ្តល់ភាពងាយស្រួលដល់ដំណើរការងារ និងការទំនាក់ទំទងគ្នារវាងរដ្ឋ និងពលរដ្ឋ និងរវាងរដ្ឋ និងវិស័យឯកជន និងដើម្បីបញ្ជ្រាបដល់ប្រជាពលរដ្ឋគ្រប់តំបន់។ រដ្ឋាភិបាលឥណ្ឌាបានបង្កើតគម្រូអភិបាលកិច្ចល្អដើម្បីបង្កើនប្រសិទ្ធភាពការផ្តល់សេវាកម្ម ការចូលរួមរបស់ប្រជាពលរដ្ឋ និងការកាត់បន្ថយអំពើពុករលួយ។ ការអនុវត្តយន្តការនេះបានធ្វើឱ្យប្រទេសឥណ្ឌាក្លាយជាប្រទេសដែលមានភាពល្បីល្បាញផ្នែកប្រជាធិបតេយ្យ។

**៤. យន្តការរដ្ឋបាលបច្ចេកវិទ្យា៖** រដ្ឋាភិបាលឥណ្ឌាបានបង្កើតរដ្ឋបាលបច្ចេកវិទ្យាដើម្បីផ្តល់ភាពងាយស្រួលដល់ការអនុវត្តការងារ ការទំនាក់ទំនង ការផ្តល់សេវាកម្មសាធារណៈ ការកាត់បន្ថយការប្រើ

ប្រាស់លិខិតស្នាម ការកាត់បន្ថយការប្រើប្រាស់ពេលវេលា ការកាត់បន្ថយការប្រើប្រាស់ថវិកា ការកាត់បន្ថយការធ្វើការទំនាក់ទំនងផ្ទាល់រវាងមន្ត្រី និងប្រជាជន ការផ្តល់សេវាកម្ម និងការផ្តល់ព័ត៌មានដល់ប្រជាជនបានគ្រប់ពេលវេលា គ្រប់ទីកន្លែងទីកន្លែង និងជាពិសេសការកាត់បន្ថយចន្លោះប្រហោង ឬអំពើពុករលួយ។ល។ នៅពេលរដ្ឋាភិបាលឥណ្ឌាចាប់ផ្តើមអនុវត្តយន្តការនេះ រដ្ឋាភិបាលទទួលបានប្រាក់រាប់ពាន់លានដុល្លារ ដែលពីមុនប្រាក់ទាំងនេះត្រូវបានកេងប្រវ័ញ្ច និងពុករលួយដោយមន្ត្រី ឬកេងបន្លំដោយពលរដ្ឋ (មន្ត្រីកិបកេងពីការអនុវត្តតួនាទីរបស់ខ្លួន ផ្សំគំនិតជាមួយឈ្មួញលើការបង់ពន្ធ ឬប្រជាពលរដ្ឋក្រីក្រប្រើប្រាស់បណ្ណក្រីក្របន្លំបើកប្រាក់ពីកន្លែងមួយទៅកន្លែងមួយទៀត) ។ល។ បន្ទាប់ពីការចាប់ផ្តើមការប្រើប្រាស់រដ្ឋាបាលបច្ចេកវិទ្យា អំពើរទាំងនោះត្រូវបានកាត់បន្ថយស្ទើរតែទាំងស្រុង ហើយរដ្ឋទទួលបានប្រាក់ចំណូលគ្រប់គ្រាន់ និងចំណាយប្រាក់ចំគោលដៅ។

**៥. យន្តការបង្កើតហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា៖** រដ្ឋាភិបាលឥណ្ឌាបានបង្កើតអែបជាច្រើនដើម្បីជួយសម្រួលដល់ការងាររបស់មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ អែបខ្លះៗក្នុងចំណោមអែបទាំងនោះរួមមាន៖ (១) GeM (Government E-Marketplace) ជាអែបសម្រាប់តែមន្ត្រីរាជការប៉ុណ្ណោះដើម្បីប្រើប្រាស់ក្នុងដំណើរការលទ្ធកម្ម(រដ្ឋាភិបាលបញ្ចូលមុខទំនិញចាំបាច់ៗ ដែលត្រូវបានប្រើប្រាស់នៅក្នុងការិយាល័យ ដូច្នេះស្ថាប័នរដ្ឋនីមួយៗអាចបញ្ជាទិញបានតាមអែបនេះទៅតាមតម្លៃដែលបានកំណត់នៅក្នុងនោះ និងដឹកជញ្ជូនដល់កន្លែងដោយមិនគិតកម្រៃជើងសារ) (២) UPI (Unified Payment Interface) ជាអែបដែលរដ្ឋាភិបាលបង្កើតឡើងដើម្បីជួយសម្រួលដល់ការចំណាយសាច់ប្រាក់ជាទូទៅ (ស្កែនដើម្បីចំណាយសាច់ប្រាក់បានគ្រប់ទីកន្លែង និងគ្រប់ស្រទាប់វណ្ណៈ) (3) GIN ជាប្រភេទអែបសម្រាប់ការធ្វើអាជីវកម្មខ្នាតតូច និងខ្នាតធំដើម្បីសម្គាល់ផលិតផលដែលត្រូវបានផលិតនៅក្នុងស្រុក (Made in India) (៤) CoWIN ជាអែបមួយដែលត្រូវបានបង្កើតឡើងដើម្បីជួយឱ្យមន្ត្រីរាជការ និងប្រជាជនអាចចុះឈ្មោះចាក់វ៉ាក់សាំងបាន។ល។

**៦. ការប្រើប្រាស់បច្ចេកវិទ្យាក្នុងដំណើរការនៃការធ្វើលទ្ធកម្មរបស់រដ្ឋ៖** រដ្ឋាភិបាលឥណ្ឌាបានរកឃើញថា ការកេងប្រវ័ញ្ច និងការបង្កើតអំពើពុករលួយបានកើតចេញមកពីការទិញទំនិញដោយផ្ទាល់របស់ស្ថាប័នរដ្ឋជាមួយនឹងឈ្មួញឯកជន (ការធ្វើលទ្ធកម្មរបស់ស្ថាប័នរដ្ឋ)។ ដើម្បីកាត់ផ្តាច់ការកេងប្រវ័ញ្ចពីការធ្វើលទ្ធកម្មរបស់ស្ថាប័នរដ្ឋ រដ្ឋាភិបាលឥណ្ឌាបានបង្កើតអែបមួយដែលមានឈ្មោះថា GeM (Government E-Marketplace)។ អែបនេះត្រូវបានប្រើប្រាស់ដោយស្ថាប័នរដ្ឋដើម្បីបញ្ជាទិញទំនិញ ឬសម្ភារៈសម្រាប់ប្រើប្រាស់នៅក្នុងស្ថាប័ន។ រដ្ឋាភិបាលបានបញ្ចូលមុខទំនិញគ្រប់ប្រភេទដែលស្ថាប័នរដ្ឋត្រូវការ និងបានកំណត់តម្លៃសមរម្យតាមមុខទំនិញនីមួយៗ។ ក្នុងករណីស្ថាប័នរដ្ឋត្រូវការបញ្ជាទិញសម្ភារៈដើម្បីប្រើប្រាស់នៅក្នុងស្ថាប័ន ពួកគេតម្រូវឱ្យបញ្ជាទិញ និងចំណាយតាមអែបនេះ (បន្ទាប់ពីបញ្ជាទិញរួចទំនិញទាំងនោះត្រូវបានដឹកជញ្ជូនដល់ស្ថាប័នដោយមិនគិតពីកម្រៃជើងសារ)។ ការអនុវត្តយន្តការនេះ បានធ្វើឱ្យរដ្ឋាភិបាលឥណ្ឌាសល់សាច់ប្រាក់រាប់ពាន់លានដុល្លារដែលពីមុន

សាច់ប្រាក់ទាំងនេះត្រូវបានមន្ត្រីលទ្ធកម្មកេងប្រវ័ញ្ចតាមរយៈការបញ្ជាទិញ និងចំណាយសាច់ប្រាក់ដោយផ្ទាល់។

**៧. គម្រោងស្តារប្រទេស៧៣គម្រោង៖** រដ្ឋាភិបាលឥណ្ឌាបានបង្កើតគម្រោងចំនួន៧៣គម្រោងជាអាទិភាព (Flagship programs/Developmental Schemes) ក្នុងការស្តារ និងអភិវឌ្ឍន៍ប្រទេស។ នៅក្នុងចំណោមគម្រោងទាំង៧៣នេះ មានគម្រោងខ្លះបានបញ្ចប់ដោយទទួលបានលទ្ធផលជោគជ័យ១០០% ដូចជា គម្រោងការគាំពារមាតា និងទារក គម្រោងបង្កន់អនាម័យ គម្រោងបញ្ចូលទិន្នន័យពលរដ្ឋម្នាក់ៗដោយប្រើប្រាស់អែប Aadhaar ជាដើម។ បច្ចុប្បន្ន រដ្ឋាភិបាលឥណ្ឌាកំពុងដំណើរការគម្រោងអាទិភាពសរុបចំនួន ២១គម្រោង។ តាមរយៈការតាំងចិត្ត ការរៀបចំផែនការច្បាស់លាស់ ការចូលរួមអនុវត្តផែនការ និងការតាមដានវាយតម្លៃផែនការជាប្រចាំពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់ជាតិ រដ្ឋាភិបាលឥណ្ឌាបានកំណត់ថា ប្រទេសឥណ្ឌានឹងក្លាយជាប្រទេសអភិវឌ្ឍន៍នៅក្នុងឆ្នាំ២០៤៧ ហើយក៏ជាការរំលឹកខួប១០០ឆ្នាំ នៃការទទួលបានឯករាជ្យភាពពីអាណានិគមនិយមអង់គ្លេសផងដែរ។

**៨. យន្តការបង្កើតការផលិតក្នុងស្រុក** (Made in India)៖ រដ្ឋាភិបាលឥណ្ឌាបានជម្រុញការបង្កើត និងការលើកទឹកចិត្តក្នុងការប្រើប្រាស់ផលិតផលក្នុងស្រុក។ ផលិតផលក្នុងស្រុកត្រូវបានចែកចាយគ្រប់ទីកន្លែង និងមានតម្លៃសមរម្យដែលអាចជួយសម្រួលដល់ប្រជាពលរដ្ឋគ្រប់ស្រទាប់មានលទ្ធភាពក្នុងការទិញផលិតផលទាំងនោះបាន។ ផលិតផលទាំងនេះត្រូវបានធ្វើចរន្តទាំងនៅក្នុងស្រុក និងនាំចេញទៅក្រៅប្រទេស។ ប្រជាពលរដ្ឋឥណ្ឌាបានប្រើប្រាស់ផលិតផលក្នុងស្រុកស្ទើរតែ៩៥%។ យន្តការនេះហើយបានធ្វើឱ្យចរន្តសាច់ប្រាក់មានដំណើរការល្អនៅក្នុងប្រទេស និងជួយស្តារសេដ្ឋកិច្ចរបស់ឥណ្ឌាឱ្យកាន់តែរីកចំរើនខ្លាំងឡើង។

**៩. ការបង្កើតមជ្ឈមណ្ឌលជាតិដើម្បីអភិបាលកិច្ចល្អ(NCGG)៖** រដ្ឋាភិបាលឥណ្ឌាបានបង្កើតមជ្ឈមណ្ឌលអភិបាលកិច្ចល្អ (National Center for Good Governance) ដើម្បីសិក្សាស្រាវជ្រាវរកធាតុចូលដល់រដ្ឋាភិបាលក្នុងការកសាង និងការអភិវឌ្ឍន៍ប្រទេស។ មជ្ឈមណ្ឌលនេះបានដើរតួជាស្នូលនៅក្នុងបណ្តុះបណ្តាលមន្ត្រីរាជការទាំងមន្ត្រីទើបតែប្រឡងជាប់ និងមន្ត្រីដែលបានបម្រើការងារដើម្បីឱ្យពួកគេបានយល់ដឹងពីគោលការណ៍ ការវាយតម្លៃ ឬការលើកទឹកចិត្តនៃការអនុវត្តគោលនយោបាយអភិបាលកិច្ចល្អ។ លើសពីនេះទៀត មជ្ឈមណ្ឌលនេះ ក៏ត្រូវបានប្រើប្រាស់ជាកន្លែងបណ្តុះបណ្តាលគោលនយោបាយសាធារណៈ និងអភិបាលកិច្ចល្អដល់មន្ត្រីស៊ីវិលមកពីប្រទេសផ្សេងៗរួមមាន៖ កម្ពុជា ប៉ាហ្គីស្ថាន ណេប៉ាល់ ប៊ូតាន ប្រទេសមួយចំនួននៅអាហ្វ្រិក និងឥណ្ឌូនេស៊ី ជាដើម។ យន្តការនេះបានជម្រុញប្រទេសឥណ្ឌាឱ្យមានការរីកចម្រើនកាន់តែខ្លាំងឡើង ជាពិសេសលើវិស័យទំនាក់ទំនង និងការទូត។